CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 15 ខែមករា ឆ្នាំ 2021

ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងភ្នំពេញ, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយ ភ្លាមៗ

# ឡុងប៊ិចរាយការណ៍ អំពីមរណភាពទីមួយ ដោយសារ COVID-19 របស់និយោជិតក្រុង

ទីក្រុងឡុងប៊ិច, រដ្ឋ CA - ថ្ងៃនេះ សាលាក្រុងឡុងប៊ិច បានប្រកាសពី មរណភាពទីមួយ ដោយសារភាពស្មុគ្រស្មាញ ពាក់ព័ន្ធនឹង COVID-19 របស់និយោជិតក្រុងម្នាក់ ។ និយោជិត ដែលជាមន្ត្រីការិយាល័យកំសាន្ត នៅនាយកដ្ឋានឧទ្យាន ការកំសាន្ត និងសមុទ្រ បានបម្រើការងារនៅសាលាក្រុង ច្រើនជាង ប្រាំឆ្នាំ មកហើយ ។

ចៅហ្វាយក្រុងលោក រ៉ូប៊ើត ហ្គាសៀ (Robert Garcia) បានគូសបញ្ជាក់ថា «នេះធ្វើឱ្យខ្ញុំស្លុតចិត្ត ដែលត្រូវបាត់បង់សមាជិកម្នាក់ របស់គ្រួសារក្រុងរបស់យើង ហើយថ្ងៃនេះ យើងយល់ច្បាស់ពីទឹកចិត្ត របស់មនុស្សជាទីស្រឡាញ់ របស់ពួកគេ ។»

និយោជិត ជាប្រជាពលរដ្ឋឡុងប៊ិច ដែលនៅធ្វើការថ្ងៃចុងក្រោយបំផុត នៅថ្ងៃទី 28 ខែធ្នូ ។

អ្នកគ្រប់គ្រងក្រុងលោក ថម ម៉ូឌីកា (Tom Modica) បានលើកឡើងថា «យើងកំពុងសោកសៅ អំពីការបាត់បង់និយោជិតរូបនេះ ដែលបានធ្វើការលះបង់ ដើម្បីធ្វើឱ្យទីក្រុងឡុងប៊ិច កាន់តែប្រសើរឡើង ។» «ខ្ញុំសូមថ្លែងអំណរគុណ ដល់ការប្តេជ្ញាចិត្ត និងសេវាបម្រើការងារ របស់គាត់ ចំពោះឡុងប៊ិច ហើយសូមរំលែកភាពសោកសៅ ជាមួយគ្រួសារ និងមិត្តភក្តិរបស់គាត់ ។

ដោយសារក្តីបារម្ភ អំពីឯកជនភាព សាលាក្រុងនឹងមិនបញ្ចេញឈ្មោះ ឬសេចក្តីលំអិត បន្ថែមទៀត អំពីបុគ្គលនេះទេ ។ សាលាក្រុងផ្តល់ជូន អ្នកប្រឹក្សា ដល់និយោជិត ពេលមានការបាត់បង់បែបនេះ ។

ត្រឹមថ្ងៃនេះ ប្រជាពលរដ្ឋឡុងប៊ិចចំនួន 520 នាក់ បានបាត់បង់ជីវិត ដោយសារ COVID-19 ។

# # #